**ឆ្នាំនៃសកម្មភាពសម្រាប់ដំណាំស្រូវរបស់ប្រជាជន (យ៉ូរ៉ា)**

**បណ្តាញសកម្មភាពថ្នាំពុលអាស៊ី និងប៉ាស៊ីហ្វិក សហការជាមួយ សេដាក**

# សំនួរដែលតែងតែចោទសួរជាញឹកញាប់ អំពី យ៉ូរ៉ា

## ១- តើអ្វីជា យ៉ូរ៉ា?

យ៉ូរ៉ា គឺមកពីពាក្យ ឆ្នាំនៃសកម្មភាពសម្រាប់ដំណាំស្រូវ។ វាគឺជាសកម្មភាពពេញមួយឆ្នាំសម្រាប់ការថែរក្សា និងការពារពូជស្រូវរបស់កសិករនៅអាស៊ី។

## ២- តើ យ៉ូរ៉ា ប្រារព្ធធ្វើនៅទីណា និងនៅពេលណា?

សកម្មភាព យ៉ូរ៉ា នឹងប្រារព្ធធ្វើក្នុងពេលវេលាផ្សេងៗគ្នា ក្នុងកំឡុងពេលពេញមួយឆ្នាំ ចាប់ផ្តើមពីថ្ងៃទី 0៤ ខែមេសា ឆ្នាំ ២00៩ ដល់ថ្ងៃទី 0៤ ខែមេសា ឆ្នាំ ២0១0 នៅក្នុងប្រទេសចំនួន ១៤ នៅអាស៊ី។ ប្រទេសទាំងនោះរួមមាន: ប្រទេសចិន ជប៉ុន កូរ៉េ កម្ពុជា វៀតណាម ថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន ស្រីលង្ការ ឥណ្ឌា ប៉ាគីស្ថាន ណេប៉ាល់ និងប្រទេសបង់ក្លាដេស។

## ៣- ហេតុអ្វីយើងចាំបាច់ត្រូវមាន យ៉ូរ៉ា?

ភាគច្រើននៃប្រជាជន ៣ ពាន់លាននាក់នៅអាស៊ី (ពាក់កណ្តាលនៃប្រជាជនក្នុងពិភពលោក) រស់នៅពឹងផ្អែកលើស្រូវ-អង្ករ ជាចំណីអាហារសំខាន់របស់ពួកគេ។ យើងត្រូវការ យ៉ូរ៉ា ពីព្រោះដំណាំស្រូវគឺជាជីវិតរបស់ប្រជាជនអាស៊ី ហើយវាកំពុងរងការគំរាមកំហែង។ វិបត្តិស្រូវ-អង្ករឆ្នាំ ២00៨ គឺជាការដាស់តឿនដ៏ធំមួយ ដែលអំពាវនាវទៅកាន់មនុស្សគ្រប់រូបថា ប្រជាជនអាស៊ីកំពុងតែបាត់បង់នូវអធិបតេយ្យភាព និងសុវត្ថិភាពចំណីអាហារ។ គ្រួសារកសិករធ្វើស្រែខ្នាតតូច ដែលបានទ្រទ្រង់ផលិតកម្មស្រូវរបស់យើង ដោយអនុវត្តនូវវិធីសាស្រ្តដាំដុះប្រកបដោយសុវត្ថិភាពតាមគោលការណ៍ធម្មជាតិរាប់រយឆ្នាំមកហើយនោះ ត្រូវបានរលាយបាត់ជាប្រព័ន្ធនៅទសវត្សរ៍ថ្មីៗនេះដោយសារកសិកម្មដែលរួមគ្នា និងកសិកម្មដែលធ្វើឱ្យវិនាស និងគោលនយោបាយពាណិជ្ជកម្ម។ ផ្ទៃដីដាំស្រូវសិរីរាង្គជាលក្ខណ:គ្រួសាររបស់យើងត្រូវ បានជំនួសដោយដំណាំស្រូវជាលក្ខណ:សហគ្រាស ជាមួយនឹងជីគីមីសំយោគ និងថ្នាំពុលគីមីសំលាប់សត្វល្អិតខណ: ដែលដីស្រែដែលមានតម្លៃថ្លៃត្រូវបានបាត់បង់ទៅជាតំបន់សេដ្ឋកិច្ច ពិសេស តំរោងអភិវឌ្ឍន៍ និងចំការធំៗ។ លើសពី នេះទៅទៀត ពូជស្រូវក្នុងស្រុករបស់យើងត្រូវបានជំនួសដោយពូជបង្កាត់ ដែលជាកម្មសិទ្ធិសារជីវកម្ម និងក្រុមហ៊ុនឯកជនធំៗ និងពូជស្រូវ ដែលប្រើប្រាស់ធនធានខាងក្រៅច្រើន។ ក្នុងពេលដ៏ឆាប់ខាងមុខ ពូជស្រូវបង្កាត់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស និង បរិស្ថាន នឹងត្រូវបានផលិតលក់

លើកលែងតែយើងបញ្ឈប់វាកុំឱ្យកើតឡើង។ វិធីសាស្ត្រតែមួយគត់ដើម្បីថែរក្សាពូជស្រូវ និងអធិបតេយ្យភាពស្បៀង (ស្រូវ) គឺយើងត្រូវតែការពារដំណាំស្រូវរបស់យើងទាំងអស់គ្នា។

## ៤- តើអ្វីគឺជាប្រធានបទរបស់ យ៉ូរ៉ា?

ប្រធានបទរបស់ យ៉ូរ៉ា គឺ **"ស្រូវជាជីវិតរបស់យើង"** - វាឆ្លុះបញ្ចាំងពីសារសំខាន់នៃស្រូវអង្ករចំពោះជីវិត និងការរស់នៅរបស់ប្រជាជនអាស៊ី។ "ស្រូវសម្រាប់ជីវិត" បង្ហាញពីវប្បធម៌ សារសំខាន់នៃផ្នែកស្មារតី និងឱជារសរបស់ស្រូវចំពោះអាស៊ី។ វាក៏បញ្ជាក់ផងដែរថា ស្រូវត្រូវតែមានសុវត្ថិភាពចំពោះកសិករអ្នកដាំ សុវត្ថិភាពចំពោះបរិស្ថាន និងសុវត្ថិភាពចំពោះអ្នកប្រើប្រាស់ក្នុងការបរិភោគ។ "ស្រូវសម្រាប់ការរស់នៅ" សំដៅដល់សទ្ធិរបស់កសិករក្រីក្រនៅទូទាំងអាស៊ី ក្នុងការរស់នៅប្រកបដោយនិរន្តរភាព។ កសិករទាំងនេះកំពុងតែប្រឹងប្រែងរស់ទាំងក្តីសង្ឃឹមតិចតួចបំផុត ដូចជា: នៅក្នុងទំរង់ពាណិជ្ជកម្មសេរី, គំរោងដែលតាំងខ្លួនថាជាគំរោងអភិវឌ្ឍន៍, ដំណាំដាំសម្រាប់លក់, ដំណាំជីវ-កសិកម្ម, ការគ្រប់គ្រងដោយសារជីវកម្មដល់ដំណាំកសិកម្ម និងគ្រាប់ពូជ, ការបាត់បង់ដីស្រែ និងការប្រែប្រួលអាកាសធាតុ។

## ៥- តើអ្វីជាសេចក្តីអំពាវនាវរបស់ យ៉ូរ៉ា?

ដោយបានដាក់ចេញនូវប្រធានបទ "ដំណាំស្រូវសម្រាប់ជីវិត និងការរស់នៅ "សេចក្តីអំពាវនាវគឺមានដូចខាងក្រោម:

- សន្សំសំចៃស្រូវ-អង្ករនៅអាស៊ី
- សុវត្ថិភាពស្រូវ-អង្ករ និងអធិបតេយ្យភាពស្រូវសម្រាប់អាស៊ី
- ស្រូវប្រកបដោយសុវត្ថិភាពសម្រាប់ទាំងអស់គ្នា
- ការពារពូជស្រូវក្នុងស្រុក
- គ្មានប្រកាសនីយប័ត្រកម្មលើពូជស្រូវ
- មិនមានការបង្ខាត់ពូជស្រូវ
- ថែរក្សាដីស្រែរបស់យើង
- ការពារអធិបតេយ្យភាពស្បៀងជូនដល់កសិករក្រីក្ររបស់យើង
- ការពារអធិបតេយ្យភាពស្បៀងជូនដល់អ្នកប្រើប្រាស់របស់យើង
- ស្រូវ-អង្ករ សិរីរាង្គសម្រាប់ទាំងអស់គ្នា

## ៦- តើនរណាកំពុងរៀបចំ យ៉ូរ៉ា?

គឺយុទ្ធនាការសន្សំសំចៃស្រូវរបស់យើង () របស់បណ្តាញសកម្មភាពថ្នាំពុលអាស៊ី និងប៉ាស៊ីហ្វិក (ភែនអេភី)។ យុទ្ធនាការនេះមានបណ្តាញដៃគូនៅក្នុងប្រទេសចំនួន ១៤ នៅអាស៊ី។ នៅក្នុងប្រទេសនិមួយៗនៃប្រទេសទាំង ១៤

អង្គការដៃគូ នឹងរៀបចំសកម្មភាព យ៉ូរ៉ា ប្លែកៗពីគ្នាជាមួយនឹងបណ្ដាញដៃគូក្នុងស្រុករបស់ពួកគេ នៅពេលវេលាផ្សេងៗគ្នាក្នុងរវាងពេញមួយឆ្នាំ។

*(*) នៅឆ្នាំ ២០០៣ (កែនអេភី) បានប្រារព្ធនូវយុទ្ធនាការសន្សំសំចៃស្រូវរបស់យើង ក្នុងគោលបំណងទទួលស្គាល់នូវសារៈសំខាន់នៃដំណាំស្រូវចំពោះអាស៊ី។ មូលដ្ឋានគ្រឹះនៃយុទ្ធនាការ គឺសរសរទាំង ៥ នៃឧត្ដមគតិដំណាំស្រូវៈ (១) វប្បធម៌ស្រូវ, (២) ឧត្ដមគតិសហគមន៍, (៣) កសិកម្មតាមគោលការណ៍ធម្មជាតិដែលផ្អែកលើជីវៈចំរុះ, (៤) សុវត្ថិភាពចំណីអាហារ និង (៥) អធិបតេយ្យភាពស្បៀង។ យុទ្ធនាការ បានចង្អុលប្រាប់ឱ្យធ្វើការសន្សំសំចៃដំណាំស្រូវជាលក្ខណៈប្រពៃណីក្នុងស្រុក, កសិករក្រីក្រ, ផ្ទៃដីដំណាំស្រូវ និងកេរ្តិ៍ដំណែលដំណាំស្រូវអាស៊ី តាមរយៈការជម្រុញការការពារអធិបតេយ្យភាពស្បៀងរបស់កសិករនៅមូលដ្ឋាន និងការប្រឆាំងដាច់ខាតចំពោះការគំរាមកំហែងដ៏មានឥទ្ធិពលទាំងឡាយណាដល់ដំណាំស្រូវ។*

## ៧- តើសកម្មភាពអ្វីខ្លះដែលរំពឹងនៅក្នុងកំឡុងពេល យ៉ូរ៉ា?

សកម្មភាពប្លែកៗគ្នា នៅក្នុងប្រទេសរៀងៗខ្លួន នឹងត្រូវរាប់បញ្ចូល (តែមិនកំណត់ទេ) ដែលរួមមានៈ ចលនាសកម្មភាពជាលក្ខណៈទ្រង់ទ្រាយធំ សិក្ខាសាលា សមាជ ទិវាដំណាំស្រូវ ការបណ្ដុះបណ្ដាល ការប្រលងប្រជែង និងការតាំងពិព័រណ៍ជាដើម។

## ៨- តើ យ៉ូរ៉ា ពាក់ព័ន្ធនឹងខ្ញុំយ៉ាងដូចម្ដេច?

ទាំងប្រជាជនអាស៊ី ឬមិនមែនអាស៊ី ប្រសិនបើអ្នកញ៉ាំបាយ ពេលនោះ យ៉ូរ៉ា គឺពិតជាមានពាក់ព័ន្ធជាមួយអ្នក។ យ៉ូរ៉ា អំពាវនាវដើម្បីឱ្យមានស្រូវ-អង្ករគ្រប់គ្រាន់សម្រាប់អ្នក និងគ្រួសារអ្នក ស្រូវ-អង្ករដែលអាចមានលទ្ធភាពទិញបាន ស្រូវ-អង្ករដែលមានឱជារស និងសុវត្ថិភាពក្នុងការបរិភោគ។ ស្រូវ-អង្ករសម្រាប់ពិធីបុណ្យទានរបស់អ្នក, ស្រូវ-អង្ករសម្រាប់ជីវិត និងការរស់នៅរបស់អ្នក។ ដំណាំស្រូវគឺជាកេរ្តិ៍មរតករបស់យើង ដែលយើងត្រូវតែរួបរួមគ្នាដើម្បីការពារមរតកនេះ។ ដូច្នេះអ្នកគ្រប់គ្នា ត្រូវបានអញ្ជើញឱ្យចូលរួម។

អ្វីដែលសំខាន់ ដែលត្រូវចងចាំ គឺថាអ្នកអាចធ្វើឱ្យមានការខុសប្លែកមួយ។ អ្នកអាចសន្សំសំចៃស្រូវអង្កររបស់អាស៊ី។ ប៉ុន្តែប្រសិនបើអ្នកមិនធ្វើអ្វីទាំងអស់ ពេលនោះយើងនឹងបាត់បង់នូវកេរ្តិ៍មរតកស្រូវអង្កររបស់យើង។

## ៩- តើខ្ញុំអាចចូលរួមជាមួយ យ៉ូរ៉ា តាមវិធីណា?

ខាងក្រោមនេះ គឺជាការរាយឈ្មោះអង្គការដៃគូទាំងចំនួន ១៤ ប្រទេស យ៉ូរ៉ា។ សូមទាក់ទងជាមួយនឹងអង្គការនៅក្នុងប្រទេសរបស់អ្នក ដើម្បីចូលរួមជាមួយសកម្មភាព យ៉ូរ៉ា។ បណ្ដាសកម្មភាពរបស់ យ៉ូរា ផ្សេងៗ អាចរកបាននៅក្នុង

គេហទំព័រ យ៉ូរ៉ា www.panap.net/yora ហើយសកម្មភាពវីដេអូ អាចទស្សនាបាននៅ http://www.youtube.com/watch?v=630otuI0Ocw ។

អ្នកអាចចូលរួមចែករំលែកមកដល់យើងខ្ញុំជាសំណូមពរ អត្ថបទចុះផ្សាយ ចំរៀង គំនូរ ឬបរិច្ចាគជាលុយកាក់។ សូមសរសេរមកកាន់យើងខ្ញុំ តាមរយៈ panap@panap.net ។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងលោកយី គីមថាន: លេខទូរស័ព្ទ ០១២ ៩៩៨ ៦៩៥

## ១០-តើអង្គការដៃគូនៅក្នុងប្រទេសផ្សេងៗគ្នាទាំងនោះមានអ្វីខ្លះ?

| NAME | POSITION | ORGANIZATION | MAILING ADDRESS | TELEPHONE | |
|---|---|---|---|---|---|
| Mr. Muhammad Asim Yasin | Managing Director | Lok Sanjh Foundation | 494 St 47 G-10/4<br>Islamabad, Pakistan | Tel: 9251-210-1043<br>Fax: 9251-221-0395 | lok_s |
| Mr. Balram Banskota | Deputy Secretary General | All Nepal Peasants' Federation (ANPFa) | Madan Nagar Balkhu<br>Kathmandu, Nepal | Tel: 977-14288404<br>Fax: 977-14288403<br>Mobile: +97-79851018248 | anpf<br>balra |
| Ms. Hewagallage Chandrawathi | National Coordinator | Vikalpani National Women's Federation | 842/3 A,<br>Daham Mawatha,<br>Thalangama North, Malabe.<br>Sri Lanka. | Tel: +94-112744160<br>Fax:+94-112744160 | vikal<br>vikal |
| Mr. Sakiul Millat Morshed | Executive Director | SHISUK | 7/1 Block A,<br>Lalmatia, Dhaka 1207,<br>Bangladesh | Tel: 0088 01713 037796<br>Fax: 0088 02 9126235 | infoc<br>ed.sh |
| Mr. Sukanta Sen | Executive Director | BARCIK (Bangladesh Resource Centre for Indigenous Knowledge) | House # 50, Road # 27<br>Dhanmondi R/A, Dhaka 1209<br>Bangladesh<br>website: www.barcik-bd.org | Tel.: 880 2 9132372, 01725 696855 | barc<br>suka |
| Ms. Fatima Burnad | Director | Society for Rural Education and Development (SRED) | 76/37, G1. 'Z' Block,<br>9th Street, Anna Nagar West,<br>Chennai – 600040, Tamil Nadu. India | Tel:+91 44 42170702 / 42170703<br>Fax: +91 44 42170702 | burn<br>tnwf |
| Mr. Poguri Chennaiah | Secretary-National Coordination | Andhra Pradesh Vyarusaya Vruthidarula Union (APVVU /<br>A Federation of Agricultural Workers, Marginal Farmers, Fisher Folks and Forest Workers) | 6, S.B.I. Colony (2nd Floor),<br>Chittoor – 517 001<br>Andhra Pradesh, India. | Tel: +91 8572 228592<br>Fax: +918572 230804 | apvv |
| Mr. Debjeet Sarangi | Secretary | Living Farms | Plot No.1181 / 2146,<br>Ratnakarbag-2,<br>TankapaniRoad,<br>Bhubaneswa, 751018,<br>Orissa. | Tel: 0091-674-2430176<br>Mobile: +91-99-38582616 | living |
| Ms. Usha Jayakumar | Executive Director | THANAL | H-3, Jawahar Nagar,<br>Trivandrum, Kerala, India | Tel: 91-471-2727150<br>Fax: 91-471-2727150 | than<br>usha |
| Mr. Chandan | | Society For Equitable Voluntary Actions (SEVA) | 3c, Milan Apartment, 52/3,<br>Vidyayatan Sarani, Kolkata-700035<br>www.sevakolkata.org | Telefax No.2578-5590/9762/2577-6365 | seva<br>seva |

| | | | | | |
|---|---|---|---|---|---|
| Mr. Oswald Quintal | Director | Kudumbam- LEISA Network | No. 17. Highways colony, Subramaniyapuram, Tiruchirappalli – 620020. Tamil Nadu, India | Tel: 0091 431 2331842/ 0091 431 2331879<br>Fax: 0091 431 2332175<br>Mobile: 0091 98424 49125/ 0091 99429 84968 | kudu<br>kudu<br>rama |
| Mr. Vijay Jardhari | Chief Activist | Beej Bachao Andolan (Save Seeds Movement) | Upli Nagni– 249 175<br>District Tehri Garhwal<br>Uttarakhand<br>INDIA | Mobile: 0091-9411777758 | vijay |
| Ms. Shimizu Ryoko<br><br>Mr. Tasaka Koa | | NO! GMO Campaign | PRICS: Policy Research Institute for the Civil Sector<br>4-1-6-3F Akatsutsumi, Setagaya-ku<br>Tokyo, 156-0044 Japan | Tel: +81-3-3325-7861<br>fax: +81-3-3325-7955 | no-g<br>ryoko<br>tasal |
| Mr. Mao Zhongshun | Programme Officer | Pesticide Eco-Alternatives Center Yunnan (PEAC) | Apt.1216, Plot 14, Yunnan Yingxiang Residential Quarter, Chuanjin Road, Kunming-650224, Yunnan, P.R.China | Tel: +86-871-5656769<br>Fax: +86-871-5656373<br>Mobile: +86-13888-904430 | zhon<br>Rong |
| Ms. Woo Haekyung | Chief of Global Relations Team | Consumers Korea | 603 Pierson Building, 89-27 Sinmun-Ro 2Ga, Chongro-Ku, Seoul 110-761, Korea | Tel: 82-2-7358907 / 7395530<br>Fax: 82-2-7365514 | cacp<br>jokin<br>bellir |
| Ms. Montawadee Krutmechai | General Director | Foundation of Reclaiming Rural Agriculture and Food Sovereignty Action (RRAFA) | 86 Soi Ladprao 110 (Sonthiwattana 2), Ladprao Rd., Wangthonglang sub-district, Wangthonglang district, Bangkok 10310, Thailand | Tel: +662-935 2981<br>Fax: +662-935 2980 | mon<br>m.sa |
| Mr. Yi Kim Than | Programme Officer | Cambodian Center for Study and Development in Agriculture (CEDAC) | #119, Street 257, Sangkat Toeuk Loak 1, Khan Toul Kork, Phnom Penh, Cambodia<br>P.O. Box 1118 | Mobile: +855 12 998655<br>Fax: +855 23 885416 | ceda<br>ysko<br>kimtl |
| Mr. Witoro | National Coordinator | Indonesia Food Sovereignty Network (KRKP) | Sindangbarang Grande No 16, Sindangbarang, Bogor Barat, West Java, Indonesia 16617 | Tel: +62251 8423752<br>Fax: +622518423752 | adm<br>witor<br>krkp |
| Mr. Erpan Faryadi | Secretary General | Aliansi Gerakan Reforma Agraria or AGRA (Alliance of Agrarian Reform Movement) | Kompleks Taman Bumi Prima Blok H3 No.4 Rt 04/Rw 22, Jl Pasantren, Cibabat, Cimahi 40513, West Java, Indonesia | Tel: +62-22-6611419<br>+62-813-204-60079 | irfan<br>(DIR<br>agra<br>(GEN |
| Ms. Rhoda Gueta | Coordinator | Resistance and Solid Solidarity Against Agrochemical TNCs (RESIST) | 65 Tindalo Street, Project 2, Quezon City, Philippines | Tel/ Fax: +632-4352448 | roda<br>sect_ |

| | | | | | |
|---|---|---|---|---|---|
| Ms. Vu Thi Bich Hop | Executive Director | Center for Sustainable Rural Development (SRD) | # 6, No 1 Alley, Le Van Huu Street, Hanoi<br><br>www.srd.org.vn | Tel: +84-4-3943-6678<br>Fax: +84-4-3943-6649 | hop@ |
| Ms. Anni Mitin | | Southeast Asian Council For Food Security And Fair Trade (SEACON) | Lot 5-1,<br>Wisma Women's Institute Of Management (WIM)<br>7, Jalan Abang Haji Openg<br>TTDI, 60000 Kuala Lumpur<br>Malaysia | Tel: +6 03 7725 9984 (new)<br>Fax: +6 03 7725 9984<br>Mobile: +6016-2516085 | indra<br>com<br>anni<br>seac |
| Mr. Nicholas Mujah ak Ason | Secretary General | Sarawak Dayak Iban Association (SADIA) | 2nd Floor,  Lot 3176<br>Sentosa Central<br>Batu 7 , Jalan Penrisen<br>93250 Kuching. Sarawak<br>East Malaysia | Mobile: +6016-8946976 | sadia |
| Ms. Anne Lasimbang<br><br>Ms. Mary Giun | Executive Director<br><br>Socio Economic Program Coordinator | PACOS, East Malaysia | Partners of Community Organisations<br>P.O. Box 511<br>89507 Penampang<br>Sabah, Malaysia | Tel: + 6 088 712518<br><br>Fax: 88-718669 | pacc<br>anne<br>sg<br>mary |


EMPOWERING PEOPLE FOR CHANGE

PANAP

PESTICIDE ACTION NETWORK ASIA & THE PACIFIC

បណ្ដាញសកម្មភាពថ្នាំពុលអាស៊ី និងប៉ាស៊ីហ្វិក

P.O. Box 1170, 10850 Penang, Malaysia.

Telephone: +604-6570271/ 6560381

Fax: +604- 6583960

E-mail: panap@panap.net

Website: http://www.panap.net